# របៀបវារៈអង្គប្រជុំតុមូលស្តីពីផែនការសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីស (LDW)

ថ្ងៃពុធ ទី 31 ខែមីនា ឆ្នាំ 2021 | ម៉ោង 5:30-7:30 ល្ងាច

ការចូលរួមអង្គប្រជុំពីចំងាយ

សេចក្តីព្រាង

*Draft v3-12-21*

**គោលបំណងអង្គប្រជុំតុមូល៖**

អង្គប្រជុំតុមូលអំពីផែនការសម្អាតចុងផ្លូវទឹកស្ទឹងខូវ៉មមីសគឺជាវេទិកាមួយសម្រាប់អ្នកដែលរងផលប៉ះពាល់ពីការសម្អាតតាម ទីតាំងដែលមានជាតិកខ្វក់នៅតាមចុងផ្លូវទឹកស្ទឹងខូវ៉មមីស Lower Duwamish Waterway Superfund Site ដើម្បីផ្តល់ជាអនុសាសន៍ដល់ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិកក្នុងអំឡុងពេលរចនានិងសាងសង់គម្រោងសំអាត។ សូមរំលឹកផងដែរថា ទីភ្នាក់ងារ EPA បានផ្តល់នូវឯកសារយោងជូនសមាជិកតុមូលនៅកិច្ចប្រជុំតុមូលលើកដំបូង។ លោកអ្នកអាចមើលឯកសារយោងនោះនៅទីនេះ That binder can be virtually found here.

**គោលបំណងអង្គប្រជុំ ៖**

- ជំរុញការអភិវឌ្ឍនៃអង្គប្រជុំតុមូលអោយមានដំណើរការទៅមុខដោយបញ្ចប់និតិវិធីប្រតិបត្តិរបស់ក្រុមការងារតុមូលនិងពិនិត្យឡើងវិញនូវសេចក្តីព្រាងផែនការការងារក្រុមតុមូលក្នុង ឆ្នាំ 2021-2022
- ស្តាប់ការធ្វើបច្ចុប្បន្នភាពបច្ចេកទេសពីទីភ្នាក់ងារ EPA រួមទាំងស្ថានភាពសម្អាតនិងផែនការបន្ទាប់មកទៀត
- កំណត់សម្គាល់ប្រធានបទដោយផ្ទាល់ឬតាមរយៈផ្សេងទៀត ដែលទាក់ទងទៅនិងគម្រោងរចនាសំអាតនិងសកម្មភាព ដែលអាចមានសារៈសំខាន់សម្រាប់សមាជិកតុមូលក្នុងការពិភាក្សាគ្នានិងដើម្បីបង្កើតការកំណត់ពេលវេលានិងទម្រង់ការសម្រាប់ដាក់បញ្ចូលទៅក្នុងរបៀបវារៈនាពេលអនាគត។

**វិធីចូលរួម:**

ការប្រជុំនេះនឹងត្រូវបានធ្វើឡើងតាមរយៈស៊ូម Zoom ។

- សម្រាប់សំលេងនិងការមើលគ្នាឃើញជាភាសាអង់គ្លេស (តាមការសំណូមពរ) សូមប្រើតំណភ្ជាប់នេះ: https://zoom.us/j/362818756.
- បើចង់ចូលរួមតាមទូរស័ព្ទ មានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ សូមទូរស័ព្ទមកលេខ 1-253-215-8782 ។ លេខសម្គាល់ចូលរួមអង្គប្រជុំ៖ 362 818 756

**មានផ្តល់ជូនការបកប្រែភាសា៖**

- សម្រាប់ភាសាវៀតណាម, សូមទូរស័ព្ទមកលេខ **206-456-6050** លេខកូដ**: 35583#**.
- សម្រាប់ភាសាអេស្បាញ, សូមទូរស័ព្ទមកលេខ **206-456-6050** លេខកូ**: 15297#**.
- សម្រាប់ភាសាខ្មែរ, សូមទូរស័ព្ទមកលេខ **206-456-6050** លេខកូ**: 05513#**.
- មានអត្ថបទបកប្រែភាសាខ្មែរនៅក្នុងគេហទំព័រតុមូល Translated materials are provided on the Roundtable Website.
- ប្រសិនបើអ្នកចង់មើលអ្នកធ្វើបទបង្ហាញ សូមប្រើតំណភ្ជាប់នេះ: https://zoom.us/j/362818756

បន្ទប់ប្រជុំតាមអនឡាញនឹងបើកអោយអ្នកចូលរួម ចូល ៣០ នាទីមុនពេលចាប់ផ្តើមប្រជុំ។ ប្រសិនបើអ្នកមានបញ្ហាបច្ចេកទេសក្នុងការចូលអង្គប្រជុំ សូមទំនាក់ទំនងទៅ *Mishu Pham-Whipple* តាម *mishupw@triangleassociates.com* ឬ *206-605-1673.*

| ពេលវេលា | ប្រធានបទរបៀបវារៈ | សំភារៈ |
| --- | --- | --- |
| 5:00-5:30<br>ល្ងាច<br>(30 នាទី) | **ការធ្វើតេស្តបច្ចេកវិទ្យានិងទំនាក់ទំនងបណ្តាញក្រៅផ្លូវការ**<br>*គោលបំណង៖ អនុញ្ញាតឱ្យអ្នកចូលរួមយល់អំពីរបៀបចូលរួមអង្គប្រជុំពីចំងាយនិងទទួលជំនួយផ្នែកបច្ចេកវិទ្យា។*<br>1. មានជម្រើសចូលមុនគេនិងតេស្តបច្ចេកវិទ្យា<br>2. មានជម្រើសចូលក្នុងបន្ទប់បែកពីគេសម្រាប់ទំនាក់ទំនងបណ្តាញក្រៅផ្លូវការ | |
| 5:30-5:50<br>ល្ងាច<br>(20 នាទី) | **ស្វាគមន៍, ណែនាំអោយស្គាល់គ្នានិងបន្តពីកន្លែងដែលបន្សល់ទុកពីលើកមុន**<br>*គោលបំណង៖ កំណត់គោលបំណងនៃអង្គប្រជុំនិងដឹងថាអ្នកណាខ្លះចូលរួម។*<br>1. ស្វាគមន៍<br>2. ធ្វើការណែនាំអំពីសមាជិកតុមូល<br>3. រំលឹកពីតួនាទីរបស់គណៈកម្មាធិការដឹកនាំក្រុមតុមូលនិងសមាជិកបច្ចុប្បន្ន<br>4. សើរើកិច្ចប្រជុំតុមូលនិងសិក្ខាសាលាពីមុនៗឡើងវិញ<br>5. របាយការណ៍ពី EPA លើការផ្លាស់ប្តូររដ្ឋបាលសហព័ន្ធនិងអ្វីដែលត្រូវរំពឹង | ភ្ជាប់ទៅកិច្ចប្រជុំសង្ខេបតុមូលថ្ងៃទី ៣០ ខែតុលាឆ្នាំ ២០១៩ នៅលើគេហទំព័រតុមូល៖<br>Link to October 30, 2019 Roundtable Meeting Summary on Roundtable website:<br>• English<br>• Español/Spanish<br>• Tieng Viet/Vietnamese<br>• ខ្មែរ /Khmer |

| ពេលវេលា | ប្រធានបទរបៀបវារៈ | សំភារៈ |
| --- | --- | --- |
| 5:50-6:15 ល្ងាច<br>(25 នាទី) | **រដ្ឋបាលក្រុមតុមូល**<br>*គោលបំណង៖ អ្នកចូលរួមចែករំលែកការយល់ដឹងរួមគ្នាអំពីគោលបំណង និងការរំពឹង ទុករបស់ក្រុមតុមូល។*<br><br>1. ផ្តល់អនុសាសន៍ទៅ EPA ៖ យល់ព្រមអនុម័តលើនីតិវិធីប្រតិបត្តិតុមូល<br>2. ពិនិត្យឡើងវិញនូវសេចក្តីព្រាងផែនការការងារតុមូលឆ្នាំ 2020-2021៖ ក្រុមការងារសម្របសម្រួលនឹងបង្ហាញសេចក្តីព្រាងផែនការការងារសម្រាប់រយៈពេល ២ ឆ្នាំខាងមុខ។<br>3. ការពិភាក្សាគ្នា៖ ស្តាប់យោបល់របស់សមាជិកតុមូលស្តីពីសេចក្តីព្រាងផែនការការងារ ហើយតើមានប្រធានបទអ្វីខ្លះថែមទៀតដែលទាក់ទងនឹង ទីតាំងមានជាតិកខ្វក់ដែលជាចំណាប់អារម្មណ៍សម្រាប់អង្គប្រជុំនាពេលអនាគត | ភ្ជាប់ទៅនឹងនីតិវិធីប្រតិបត្តិការនៅលើគេហទំព័រតុមូល៖<br>• English<br>• Español/Spanish<br>• Tieng Viet/Vietnamese<br>• ខ្មែរ /Khmer<br>សេចក្តីព្រាងផែនការការងារតុមូលឆ្នាំ 2020-21 នៅលើគេហទំព័រតុមូល<br>Draft 2021-22 Roundtable Work Plan on Roundtable website:<br>• English<br>• Español/Spanish<br>• Tieng Viet/Vietnamese<br>• ខ្មែរ /Khmer |

| | | |
|---|---|---|
| 6:15-7:05<br>ល្ងាច<br>(50 នាទី) | **ការធ្វើបច្ចុប្បន្នភាពផ្នែកបច្ចេកទេស**<br>*គោលបំណង៖ ស្តាប់អំពីឯកសារថ្មីពី EPA ទាក់ទងនឹងការសំអាត តើអ្វីទៅជាគោលបំណងនិងអត្ថន័យនៃឯកសារទាំងនេះហើយនិងអ្វីដែលសមាជិកគុម្ពលអាចរំពឹងថានឹងកើតឡើងបន្ទាប់មកទៀត។*<br><br>1. <u>ព័ត៌មានតែប៉ុណ្ណោះ៖</u> របាយការណ៍វិនិច្ឆ័យទិន្នន័យស៊ើបអង្កេត ការរចនាជំហានដំបូងក្នុងដំណាក់កាលទី ១ សម្រាប់ទីតាំងផ្នែកខាងលើ៖ នេះគឺជាការសង្ខេបលទ្ធផលពិសោធក្នុងដំណាក់កាលទី 1 (ឆ្នាំ 2020) និងទិន្នន័យទីតាំងផ្សេងទៀតដែលទាក់ទងនឹងកម្រិតកំណត់ត្រាសកម្មភាពសម្រេចចិត្ត (ROD) ។ វាផ្តល់នូវយោបល់ដំបូងនៃកម្រិតកំណត់សម្រាប់មធ្យោបាយផែនការសម្អាតដែលមានលក្ខណៈផ្សេងៗគ្នា។ កម្រិតកំណត់ដំបូងទាំងនេះនឹងផ្លាស់ប្តូរ ប៉ុន្តែវាជួយកំណត់សម្គាល់ចន្លោះទិន្នន័យដែលត្រូវបំពេញនៅក្នុងដំណាក់កាលពិសោធលើកទី 2 (ឆ្នាំ 2021) ។ ទីភ្នាក់ងារ EPA នឹងសង្ខេបមតិយោបល់របស់ពួកគេអោយទៅក្រុមមើលខុសត្រូវសំអាតចុងផ្លូវទឹកស្ទឹងឌូវ៉មមីស (LDWG) ។<br><br>    **a.** វគ្គសំណួរនិងចម្លើយ<br><br>2. <u>ឱកាសសម្រាប់បញ្ចេញយោបល់៖</u> ផែនការគម្រោងការធានារ៉ាប់រងគុណ ភាព (QAPP) សម្រាប់ការស៊ើបអង្កេតការរចនា ជំហានដំបូងក្នុងដំណាក់ កាលទី ២ ធ្វើការពិសោធទីតាំងផ្នែកខាងលើ៖ ផែនការនេះពិពណ៌នាអំពីការពិសោធប្រភេទណាដែលក្រុមសំអាតចុងផ្លូវទឹកស្ទឹងឌូវ៉មមីស (LDWG) ស្នើសុំធ្វើការពិសោធក្នុងឆ្នាំ 2021 ។ ទីភ្នាក់ងារ EPA នឹងពន្យល់ពីអ្វីដែលមាននៅក្នុងផែនការនិងមូលហេតុរបស់វា។ សមាជិកគុម្ពលដែលមានចំ ណាប់អារម្មណ៍អាចផ្តល់ជាមតិយោបល់ជាលាយលក្ខណ៍អក្សរសម្រាប់អោយ EPA យកមកពិចារណាកុំអោយហួសថ្ងៃទី 12 ខែមេសា។ *នេះគឺមិនមែនជាពេលវេលាផ្តល់យោបល់សាធារណៈជាផ្លូវការទេ។*<br>    **a.** វគ្គសំណួរចម្លើយនិងការផ្តល់មតិទៅ EPA មុនគេបង្អស់<br>3. <u>ពេលវេលាបើកអោយបញ្ចេញមតិ៖</u> ការពន្យល់ពីភាពខុសគ្នាដែលមានចំ ណុចសំខាន់ៗអំពីជាតិ cPAHs: ព័ត៌មានអំពីការផ្លាស់ប្តូរកម្រិតសម្អាតក្នុងកំ ណត់ត្រា ROD និងកម្រិតសកម្មភាពសំអាតជាតិកខ្វក់ដែលអាចប៉ះពាល់ដល់សុខភាពមនុស្ស ត្រូវបានគេចែករំលែកនៅក្នុងសិក្ខាសាលាព័ត៌មានសហគមន៍នៅថ្ងៃទី ១៧ ខែកុម្ភៈឆ្នាំ 2021 ។ **EPA នឹងពន្យល់ពីអ្វីដែលមាននៅក្នុងសំណើរនិងពីមូលហេតុ។ សមាជិកគុម្ពលដែលមាន ចំណាប់អារម្មណ៍អាចផ្តល់ជាមតិយោបល់ជាលាយលក្ខណ៍អក្សរសម្រាប់ អោយ EPA យកមកពិចារណាកុំអោយហួសថ្ងៃទី 6 ខែមេសា ឆ្នាំ 2021 ។** | ឯកសារព្រាងរបស់គម្រោងផែនការ QAPP<br><br>តំណភ្ជាប់ទៅគេហទំព័ររបស់ក្រុមគុម្ពលពន្យល់ពីសំភារៈដែលមានសភាពខុសគ្នាក្នុងចំណុចសំខាន់ៗ<br>[Link to Explanation of Significant Differences (ESD) materials on Roundtable website] |

| ពេលវេលា | ប្រធានបទរបៀបវារៈ | សំភារៈ |
|---|---|---|
| 7:05-7:20 ល្ងាច<br>(15 នាទី) | **ព័ត៌មានអំពីទីតាំងនិងការធ្វើបច្ចុប្បន្នភាពផ្សេងៗទៀត**<br>*គោលបំណងៈ ស្តាប់ការធ្វើបច្ចុប្បន្នភាពលើប្រធានបទផ្សេងទៀត ដែលមានចំណាប់អារម្មណ៍ចំពោះក្រុមគុមូល។*<br><br>1. ការធ្វើបច្ចុប្បន្នភាពពីក្រុមការងារសុខភាពសហគមន៍អំពីការគ្រប់គ្រងស្ថាប័ន (IC)<br>2. ការធ្វើបច្ចុប្បន្នភាពខ្លីៗពីសមាជិកគុមូល | |
| 7:20-7:25 ល្ងាច<br>(5 នាទី) | **ឱកាសសម្រាប់វគ្គផ្តល់យោបល់និងសួរសំណួរពីអ្នកសង្កេតការណ៍**<br>*គោលបំណងៈ*<br>*អនុញ្ញាតឱ្យបញ្ចេញយោបល់និងសួរសំណួរដែលសមាជិកគុមូលមិនទាន់បានលើកឡើង។* | |
| 7:25-7:30 ល្ងាច<br>(5 នាទី) | **បញ្ចប់អង្គប្រជុំនិងជំហានបន្ទាប់មកទៀត**<br>*គោលបំណងៈ ធានាតាមដានគំនិតនិងភារកិច្ច។*<br>1. វិធានបទសំខាន់ៗ<br>2. ជំហានបន្ទាប់មកទៀត | |
| 7:30 ល្ងាច | **បញ្ចប់អង្គប្រជុំ** | |
| *7:30-7:45 ល្ងាច*<br>*(15 នាទី)* | ***ការសង្ខេបក្រោយអង្គប្រជុំ ស្ម័គ្រចិត្ត - EPA នឹងចាកចេញពីអង្គប្រជុំ***<br>• តើយើងអាចធ្វើយ៉ាងណាដើម្បីអោយអង្គប្រជុំបានប្រសើជាងនេះ? (ដូចជា ការរៀបចំបកប្រែភាសាការសម្របសម្រួល សំភារៈសម្រាបអង្គប្រជុំប និងទបង្ហាញ ជាដើម ។ល។) | |